# សុន្ទរកថារបស់ដៃគូអភិវឌ្ឍន៍ ស្តីពីសមាហរណកម្មនៃការធ្វើផែនការយុទ្ធសាស្ត្រ ការរៀបចំថវិកា និងការគ្រប់គ្រងជំនួយ

## ថ្លែងដោយឯកឧត្តម ម៉ាសាហ៊្វូមី គូរ៉ូគី (Masafumi Kuroki) ឯកអគ្គរាជទូតជប៉ុន ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចប្រជុំលើកទី១៨នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

## រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១

សូមគោរព ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឯកឧត្តម លោក-លោកស្រី

ដៃគូអភិវឌ្ឍន៍ សូមស្វាគមន៍ឱកាសនេះ ដើម្បីពិភាក្សាទៅលើបញ្ហាអាទិភាពរួមដែលទាក់ទងទៅនឹង *សមាហរណកម្មនៃការធ្វើផែនការយុទ្ធសាស្ត្រ ការរៀបចំថវិកា និងការគ្រប់គ្រងជំនួយ* ដែលជាសូចនាករត្រួតពិនិត្យរួម (JMI) មួយសម្រាប់ឆ្នាំ២០១០/២០១១ ។

យើងទទួលស្គាល់ការងារដែលបានអនុវត្តមកទល់នឹងពេលបច្ចុប្បន្ន ដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងវិស័យនេះ និងតួនាទីសំខាន់ៗ របស់ក្រសួងផែនការ ក្នុងការរុញច្រានដំណើរការនេះទៅមុខ ។ យើងរំពឹងថានឹងក្លាយជាចំណែក មួយនៃកិច្ចពិភាក្សាដ៏ពិតប្រាកដ លើបញ្ហាដ៏សំខាន់នេះ ហើយយើងក៏រំពឹងផងដែរថានឹងទទួលបាននូវការបញ្ជាក់យ៉ាងច្បាស់លាស់ អំពីទស្សនៈវិស័យផ្ទាល់ខ្លួនរបស់ រដ្ឋាភិបាល ។ សម្រាប់យើងខ្ញុំ វាគឺជាអាទិភាពមួយក្នុងការស្វែងយល់អំពីអន្តរទំនាក់ទំនង រវាងដំណើរការសំខាន់ៗនៃកំណែទម្រង់ ហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងសម្របសម្រួលជំនួយ ហើយយើងសូមធ្វើការ សង្កត់បញ្ជាក់អំពីការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់ យើង ក្នុងការសម្រេចឱ្យបាននូវការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធិភាព លើបញ្ហាទាំងអស់នេះ។ យើងសូមអះអាងថា យើងបានត្រៀមខ្លួនរួចរាល់ជាស្រេចដើម្បីគាំទ្រ និងជួយដល់ដំណើរការនេះ ក្នុងករណីដែលរដ្ឋាភិបាលត្រូវការ ។

នៅពេលដែលយើងបានជួបគ្នាក្នុងខែតុលា ឆ្នាំ២០១០ នាសម័យប្រជុំ GDCC លើកទី១៧ យើងត្រូវបានផ្តល់ដំបូន្មានអំពីជំហានដែលគ្រោងអនុវត្ត និងកាលបរិច្ឆេទឱសានវាទ នៅក្នុងដំណើរការសមាហរណកម្ម អាស្រ័យដោយវាពាក់ព័ន្ធទៅនឹង សូចនាករត្រួតពិនិត្យរួម សម្រាប់រៀបចំផែនការ និងកាត់បន្ថយភាពក្រីក្រ ដែលក្នុងនោះការវិភាគមួយទៅលើស្ថានភាព នឹងត្រូវបញ្ចប់ឱ្យបានរួចរាល់នៅត្រឹមខែធ្នូ ឆ្នាំ២០១០ ហើយផែនការសកម្មភាពមួយ ដើម្បីផ្សព្វផ្សាយអនុសាសន៍ដែលផ្តល់ជូនដោយការវិភាគ

ស្ថានភាព និងត្រូវបញ្ចប់ឱ្យបានរួចរាល់នៅត្រឹមខែមិថុនា ឆ្នាំ២០១១។ ដូច្នេះ កិច្ចប្រជុំ GDCC លើកទី១៨នេះ ផ្តល់នូវឱកាសដ៏ល្អប្រសើរមួយ ដើម្បីស្វែងឱ្យបានច្បាស់លាស់យល់អំពីទស្សនៈវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាសមាហរណកម្ម និងសុកដុមនីយកម្ម ដើម្បីស្វែងយល់អំពីវិសាលភាពនៃការវិភាគស្ថានភាព និងអនុសាសន៍ដែលការវិភាគនេះបានផ្តល់ជូន និងដើម្បី ពិនិត្យរកមើលវិស័យដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍អាចសហការជាមួយគ្នាបាន។ ស្ថារតីរបស់ JMIs ដែលត្រូវបានបង្កើតឡើង គឺដើម្បីសង្កត់ធ្ងន់ទៅលើតម្លៃនៃការពិគ្រោះយោបល់ នៅក្នុងដំណើរការនេះ និងការប្តេជ្ញាចិត្តក្នុងការបង្កលក្ខណៈឱ្យមានការចូលរួម ពីដៃគូអភិវឌ្ឍន៍ នៅក្នុងដំណាក់កាលរៀបចំ។

អាស្រ័យដោយការងារមកទល់នឹងពេលបច្ចុប្បន្ន ត្រូវបានអនុវត្តធ្វើឡើងជាលក្ខណៈផ្ទៃក្នុងនៅក្នុងរដ្ឋាភិបាល យើងសូមស្វែងរកធ្វើ ការពិភាក្សាបន្ថែមទៅលើបញ្ហាសំខាន់ៗចំនួនពីរ ក្នុងស្មារតីនៃការចាប់ផ្តើមកិច្ចពិភាក្សាមួយ ដែលរាប់បញ្ចូលដៃគូអភិវឌ្ឍន៍ ៈ

- ប្រមើលមើលជាមុនទៅលើទស្សនៈវិស័យទូទៅរបស់រដ្ឋាភិបាល សម្រាប់ដំណើរការសមាហរណកម្ម និងអ្វីដែលបង្កផលប៉ះពាល់ ឬទំនាក់ទំនងជាមួយ កម្មវិធីកំណែទម្រង់ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទៅលើការសម្រប សម្រួលជំនួយ ។
- ស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍន៍ផែនការសកម្មភាព ដើម្បីផ្សព្វផ្សាយអនុសាសន៍ដែលទទួលបានពីការវិភាគស្ថានភាព និងផែនការ សម្រាប់ពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ នៅក្នុងដំណើរការអភិវឌ្ឍន៍ផែនការសកម្មភាព។

ជាចុងក្រោយ យើងសូមឆ្លៀតយកឱកាសនេះ ដើម្បីទទួលស្គាល់កិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា និងការងារដែលបានអនុវត្តមកទល់នឹងពេលបច្ចុប្បន្ន ដោយភ្នាក់ងារកណ្តាលរបស់ក្រសួងផែនការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ CDC/CRDB និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ យើងសូមបញ្ជាក់ឡើងវិញនូវចំណាប់អារម្មណ៍របស់យើង ក្នុងការបន្តជាដៃគូគាំទ្រនៅក្នុងដំណើរការនេះ ហើយយើងសង្ឃឹមថាថ្ងៃនេះ យើងអាចទទួលបានការបញ្ជាក់ពីរដ្ឋាភិបាល លើផែនការសម្រាប់ពិគ្រោះយោបល់និងការពិភាក្សា ជាមួយយើង ទាក់ទងទៅនឹងការអភិវឌ្ឍន៍ផែនការសកម្មភាព អាស្រ័យដោយបញ្ហាទាំងនេះទាក់ទង ទៅនឹងក្រុមការងារបច្ចេកទេស មួយចំនួនដែលយើងចូលរួម ។ យើងរំពឹងថានឹងទទួលបាននូវកិច្ចសហប្រតិបត្តិការប្រកបដោយភាពស្ថាបនា និងផ្លែផ្កា នៅក្នុង ដំណើរការដ៏សំខាន់នេះ។

សូមអរគុណ ។